ព្រះរាជាណាចក្រកម្ពុជា

សាលាដំបូងខេត្តកំពត ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ លេខ១១១

ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩

សាលក្រមព្រហ្មទណ្ឌ លេខ៥២

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពត នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង៨ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ប្រធានសាលាដំបូង ជាប្រធាន
- លោក [redacted] ចៅក្រម ជាសមាជិក
- លោក ស្រី [redacted] ចៅក្រម ជាសមាជិក

**តំណាងអយ្យការ**

- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពត

**ដើម្បីជំនុំជម្រះ**

- ឈ្មោះ [redacted] ការុណា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ របររកស៊ី គ្រូបង្រៀន ទីកន្លែងកំណើត ភូមិក្រាំង ឃុំក្រាំងអំពិល ស្រុកកំពង់បាយ ខេត្តកំពត ទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុខ គ្មាន។ (ឃុំខ្លួនថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩)

ត្រូវជាប់ចោទពីបទ៖ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២។

អាន លោក [redacted] សុខគី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុន្នី ភេទប្រុស អាយុ៣៦ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ ចន្លោះពីម៉ោង៩និង៣០នាទីយប់ទៅម៉ោង៦ព្រឹក ឈានចូលថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ [redacted] សុភី បានឆក់ខ្សែភ្លើងស្លាប់ក្បែររបងលួសផ្ទះឈ្មោះ [redacted] ការុណា ដោយ ឈ្មោះ [redacted] ការុណា បានភ្ជាប់អគ្គិសនីទៅនឹងរបងលួសរបស់

ខ្លួន ទើបបណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] សុភី ប៉ះត្រូវឆក់ស្លាប់នៅនឹងកន្លែងតែម្តង។ ក្រោយកើតហេតុ សមត្ថកិច្ចនគរបាលបានស្រាវជ្រាវ និង សាកសួរ ឈ្មោះ [redacted] ការុណ បានសារភាព ហើយបានធ្វើការឃាត់ខ្លួន និង បញ្ជូនមកតុលាការ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ដើម្បីចាត់ការតាមច្បាប់។

-បាន ឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ៣៦ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០

-បាន ឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ៧១ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០

-បាន ឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ លេខ៩០ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០

-បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះ លេខ១៥៨ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០

**ឆាពេលសេចក្តីការ**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ការុណ បានឆ្លើយថាៈ ផ្ទះខ្លួនមិនមានភ្ជាប់ចរន្តអគ្គិសនីនឹងរបងបន្លាលួសទេ ហើយរបងផ្ទះខ្លួនតំមានតែ៣ជ្រុងប៉ុណ្ណោះ ដោយខាងមុខផ្ទះមិនមានរបងទេ។ នៅយប់ថ្ងៃកើតហេតុនោះ គឺមានភ្លៀងធ្លាក់យ៉ាងខ្លាំង ខ្លួននៅផ្ទះរហូត មិនបានទៅណាទេ។ លុះព្រឹកឡើងខ្លួនបានចេញទៅធ្វើការធម្មតា ទៅដល់ពាក់កណ្តាលផ្លូវ ស្រាប់តែប្រពន្ធខ្លួនទូរស័ព្ទហៅខ្លួនឱ្យត្រឡប់មកវិញ ដោយថាមានគេស្លាប់នៅរបងផ្ទះខ្លួន ហើយមានប៉ូលិសមកដល់ផ្ទះ ខ្លួនក៏ត្រឡប់មកផ្ទះវិញ តែខ្លួនមិនបានទៅមើលសពទេ ដោយខ្លួនបានទៅប៉ុស្តិ៍ជាមួយប៉ូលិសតែម្តង។ របងផ្ទះខ្លួន ធ្វើពីឈើកំពស់ជាងមួយម៉ែត្រ ដោយមានរាយបន្លាលួសបន្ថែម ហើយនៅក្បែររបងនោះមានរោងស័ង្កសីមួយសម្រាប់ដាក់របស់របរ។ ពីផ្ទះខ្លួនទៅរបង ខ្លួនបានភ្ជាប់ខ្សែលួសមួយខ្សែ សម្រាប់ហាលខោអាវ តែខ្លួនមិនបានភ្ជាប់ចរន្តអគ្គិសនីទៅនឹងខ្សែនោះទេ។ ខ្លួនមិនដែលប្រាប់ក្មេងៗថា ខ្លួនបានភ្ជាប់អគ្គិសនីទៅនឹងរបងទេ។ ព្រឹកក្រោយកើតហេតុ ខ្លួនមិនបានទៅសារខ្សែភ្លើងពណ៌ស ហើយខ្លួនក៏មិនដែលមានខ្សែភ្លើងពណ៌សនោះដែរ។ ខ្លួនស្គាល់ជនរងគ្រោះ ព្រោះពួកខ្លួនរស់នៅចំងាយប្រហែល៥០ម៉ែត្រពីគ្នា ពួកខ្លួនមិនដែលមានទំនាស់អ្វីនឹងគ្នានោះទេ។ នៅលើដំបូលផ្ទះបាយដែលប្រក់ស័ង្កសីរបស់ខ្លួន គឺមានខ្សែភ្លើងនៅលើនោះ តែខ្សែនោះមានស្រោប ហើយនៅផ្ទះបាយខ្លួន នោះ មានខ្សែលួសចងភ្ជាប់ទៅនឹងរបងលួសជុំវិញផ្ទះខ្លួន។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុន្នី បានឆ្លើយថាៈ ផ្ទះខ្លួនចំងាយប្រហែល៣០ម៉ែត្រ រំលងស្រែមួយពីផ្ទះ [redacted] ការុណ។ នៅយប់ថ្ងៃនោះ ជនរងគ្រោះដែលត្រូវជាប្អូនខ្លួន បានដេកនៅនឹងរោងក្បែរនោះ ជាមួយមិត្តវា ចំងាយប្រហែល២០ម៉ែត្រពីកន្លែងកើតហេតុ។ នៅព្រឹកក្រោយកើតហេតុ ឈ្មោះ [redacted] សិកា បានមកប្រាប់ខ្លួន ខ្លួនក៏ទៅមើល ឃើញប្អូនខ្លួនស្លាប់ដោយឆក់អគ្គិសនី នៅក្បែរដើមស្វាយ ដោយលែងប្រហែលជា២ម៉ែត្រកន្លះ គឺស្លាប់ដោយឆក់ជាប់នៅនឹងរបងផ្ទះ [redacted] ការុណ នោះតែម្តង។ ខ្លួនក៏បានចាត់ចែងយកសពប្អូនទៅធ្វើបុណ្យតាមប្រពៃណីនៅឯផ្ទះ ពេលនោះ ឈ្មោះ [redacted] ការុណ បានអើតមើលខ្លួន នៅពេលដែលខ្លួនលើកសពប្អូនចេញពីរបង តែមិនបានមកមើលជិតនោះទេ។ នៅលើសពប្អូនខ្លួនដែលខ្មោចស្លាប់នោះ គឺមានមែកស្វាយ ដែលមានផ្លែ ហើយអាចឈោងប៉ះដល់ នៅពីលើ តែមិនមានមែកស្វាយដែលបាក់នោះទេ។ ផ្ទះម្តុំនោះមិនដែលមានបាត់របស់របរអ្វីទេ។ ខ្លួនសង្ស័យលើឈ្មោះ [redacted] ការុណ ជាអ្នក

ភ្ជាប់ចរន្តអគ្គិសនីទៅនឹងរបងនោះ។ ចំពោះរឿងនេះ ខ្លួនទាមទារសំណង ចំនួន២០លានរៀល និង សុំឱ្យផ្តន្ទាទោសតាមច្បាប់។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ពៅ បានឆ្លើយថាៈ នៅមុនថ្ងៃដែលឈ្មោះ សុភី ឆក់ស្លាប់នោះ ឈ្មោះ [redacted] ការុណា បានប្រាប់ខ្លួន កុំឱ្យទៅលេងក្បែររបងគាត់ ប្រយ័ត្នឆក់ស្លាប់ នៅថ្ងៃមួយដែលខ្លួនទៅញ៉ាំនំនៅផ្ទះគាត់ តែខ្លួនមិនចាំថានៅថ្ងៃណានោះទេ គ្រាន់តែចាំថានៅមុន ពេលឈ្មោះ សុភី ស្លាប់។ ខ្លួនតែងតែទៅហូបនំនៅផ្ទះឈ្មោះ [redacted] ការុណា ជារៀងរាល់ថ្ងៃ។ ខ្លួនមិន បានប្រាប់ពាក្យហាមឃាត់នេះ ដល់ក្មេងៗឯទៀតនោះទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] មនសិកា បានឆ្លើយថាៈ នៅយប់នោះក្រោយពេល មកពីផឹកស៊ី នៅម៉ោងប្រហែល៩យប់ ឈ្មោះ សុភី បានមកដេកជាមួយខ្លួន និង ឈ្មោះ [redacted] គា នៅនឹងរោងវិញ ។ លុះព្រឹកឡើង ពេលខ្លួនក្រោកទៅនោម ស្រាប់តែឃើញឈ្មោះ សុភី ដេកក្បែរ របង ដោយគ្មានស្លៀកពាក់អ្វីទេ ខ្លួនស្មានថាគាត់សន្លប់ ក៏ទៅប្រាប់បងគាត់ឈ្មោះ [redacted] ប៊ុន្នី ក្រោយមក ទើបខ្លួនដឹងថាឈ្មោះ សុភី ស្លាប់។ ខ្លួនសុំបញ្ជាក់ថា ឈ្មោះ សុភី ជាធម្មតា គឺមានស្លៀកពាក់ខោអាវនៅពេលដេក។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] គា បានឆ្លើយថាៈ នៅម៉ោងប្រហែល៦និង៣០នាទី យប់ ឈ្មោះ សុភី បានចេញទៅផឹកស៊ី ហើយខ្លួនក៏បានចេញទៅមើលរឿង។ ក្រោយមកពីមើល រឿងវិញ នៅម៉ោងប្រហែល៨យប់ ខ្លួនឃើញឈ្មោះ សុភី និងឈ្មោះ មនសិកា កំពុងដេក ខ្លួនក៏ ចូលដេកដែរទៅ ពេលនោះឈ្មោះ សុភី ស្លៀកខោខ្លី និង មានពាក់អាវ។ លុះព្រឹកឡើង ឈ្មោះ សុភី ក៏ស្លាប់នៅនឹងរបងលួសផ្ទះ ឈ្មោះ [redacted] ការុណា គឺឆក់ជាប់នៅនឹងរបងនោះតែម្តង ដោយមិន បានស្លៀកពាក់អ្វីទាំងអស់ គឺមានគ្របដែលភួយសើមមួយប៉ុណ្ណោះ ពេលនោះ ខ្លួនបានទៅស្ទង់ ដង្ហើមឈ្មោះ សុភី ដែរ តែខ្លួនមិនបានប៉ះសពទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] វ៉ាន់ថន បានឆ្លើយថាៈ នៅយប់នោះ ខ្លួននឹងឈ្មោះ សុភី បានផឹកស៊ីជាមួយគ្នានៅផ្ទះមួយដែលមានចំងាយប្រហែលកន្លះគីឡូពីផ្ទះឈ្មោះ សុភី ដោយ ឈ្មោះនេះមានស្លៀកពាក់ធម្មតា លុះម៉ោងប្រហែល៩យប់ ខ្លួនបានជូនឈ្មោះ សុភី មកដល់ ត្រឹមចំងាយប្រហែល៤០ម៉ែត្រទៀតដល់ផ្ទះវា រួចខ្លួនក៏ត្រឡប់ទៅវិញ។ ពេលផឹកស៊ីនោះ មានគ្នា៧ នាក់ ដោយផឹកអស់ស្រាផែនដី ចំនួន៩ដប តែឈ្មោះ សុភី មិនស្រវឹងទេ ដោយវាឈប់ផឹកមុនគេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សឿយ បានឆ្លើយថាៈ ខ្លួនដឹងតែរឿងក្រោយពេលគេ យកសពមកដល់ផ្ទះហើយប៉ុណ្ណោះ រឿងក្រៅពីនេះ ខ្លួនមិនបានដឹងទេ។ ភូមិនោះធ្លាប់មានបាត់ មាន់ដែរ តែគឺបាត់មុនពេលឈ្មោះ [redacted] ការុណា មករស់នៅ ហើយក្រោយឈ្មោះនេះមករស់នៅ គឺមិនដែលមានបាត់មាន់ទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារី បានឆ្លើយថាៈ ខ្លួនដឹងតែរឿងក្រោយពេលគេ យកសពមកដល់ផ្ទះហើយប៉ុណ្ណោះ រឿងក្រៅពីនេះ ខ្លួនមិនបានដឹងទេ។ ដើមស្វាយនោះជាដើម ស្វាយរបស់ខ្លួន។ ខ្លួនមិនបានឮថា ឈ្មោះ [redacted] ការុណា បានភ្ជាប់ចរន្តអគ្គិសនីនៅនឹងរបងទេ។ ផ្ទះឈ្មោះ [redacted] ការុណា មានគ្នាប្រហែលពី៤ទៅ៥នាក់។ តាំងពីឈ្មោះនេះមករស់នៅភូមិនេះ ផ្ទះគាត់មិនដែលបាត់មាន់ទេ។



CamScanner

ភ្ជាប់ចរន្តអគ្គិសនីទៅនឹងរបងនោះ។ ចំពោះរឿងនេះ ខ្លួនទាមទារសំណង ចំនួន២០លានរៀល និង សុំឱ្យផ្តន្ទាទោសតាមច្បាប់។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ពៅ បានឆ្លើយថា: នៅមុនថ្ងៃដែលឈ្មោះ សុភី ឆក់ស្លាប់នោះ ឈ្មោះ [redacted] ភារុណ បានប្រាប់ខ្លួន កុំឱ្យទៅលេងក្បែររបងគាត់ ប្រយ័ត្នឆក់ស្លាប់ នៅថ្ងៃមួយដែលខ្លួនទៅញ៉ាំនំនៅផ្ទះគាត់ តែខ្លួនមិនចាំថានៅថ្ងៃណានោះទេ គ្រាន់តែចាំថានៅមុនពេលឈ្មោះ សុភី ស្លាប់។ ខ្លួនតែងតែទៅហូបនំនៅផ្ទះឈ្មោះ[redacted]ភារុណ ជារៀងរាល់ថ្ងៃ។ ខ្លួនមិនបានប្រាប់ពាក្យហាមឃាត់នេះ ដល់ក្មេងៗឯទៀតនោះទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]មនសិកា បានឆ្លើយថា: នៅយប់នោះក្រោយពេលមកពីផឹកស៊ី នៅម៉ោងប្រហែល៩យប់ ឈ្មោះ សុភី បានមកដេកជាមួយខ្លួន និង ឈ្មោះ[redacted] តា នៅនឹងរោងវិញ ។ លុះព្រឹកឡើង ពេលខ្លួនក្រោកទៅនោម ស្រាប់តែឃើញឈ្មោះ សុភី ដេកក្បែររបង ដោយគ្មានស្លៀកពាក់អ្វីទេ ខ្លួនស្មានថាគាត់សន្លប់ ក៏ទៅប្រាប់បងគាត់ឈ្មោះ [redacted] ចន្ទី ក្រោយមក ទើបខ្លួនដឹងថាឈ្មោះ សុភី ស្លាប់។ ខ្លួនសុំបញ្ជាក់ថា ឈ្មោះ សុភី ជាធម្មតាគឺមានស្លៀកពាក់ខោអាវនៅពេលដេក។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] តា បានឆ្លើយថា: នៅម៉ោងប្រហែល៦និង៣០នាទីយប់ ឈ្មោះ សុភី បានចេញទៅផឹកស៊ី ហើយខ្លួនក៏បានចេញទៅមើលរឿង។ ក្រោយមកពីមើលរឿងវិញ នៅម៉ោងប្រហែល៨យប់ ខ្លួនឃើញឈ្មោះ សុភី និងឈ្មោះ មនសិកា កំពុងដេក ខ្លួនក៏ចូលដេកដែរទៅ ពេលនោះឈ្មោះ សុភី ស្លៀកខោខ្លី និង មានពាក់អាវ។ លុះព្រឹកឡើង ឈ្មោះ សុភី ក៏ស្លាប់នៅនឹងរបងលួសផ្ទះ ឈ្មោះ[redacted]ភារុណ គឺឆក់ជាប់នៅនឹងរបងនោះតែម្តង ដោយមិនបានស្លៀកពាក់អ្វីទាំងអស់ គឺមានគ្រប់ដែលភួយសើមមួយប៉ុណ្ណោះ ពេលនោះ ខ្លួនបានទៅស្ទង់ដង្ហើមឈ្មោះ សុភី ដែរ តែខ្លួនមិនបានប៉ះសពទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]ភ័ន់ថន បានឆ្លើយថា: នៅយប់នោះ ខ្លួននឹងឈ្មោះ សុភី បានផឹកស៊ីជាមួយគ្នានៅផ្ទះមួយដែលមានចំងាយប្រហែលកន្លះគីឡូពីផ្ទះឈ្មោះ សុភី ដោយឈ្មោះនេះមានស្លៀកពាក់ធម្មតា លុះម៉ោងប្រហែល៩យប់ ខ្លួនបានជូនឈ្មោះ សុភី មកដល់ត្រឹមចំងាយប្រហែល៥០ម៉ែត្រទៀតដល់ផ្ទះវា រួចខ្លួនក៏ត្រឡប់ទៅវិញ។ ពេលផឹកស៊ីនោះ មានគ្នា៧នាក់ ដោយផឹកអស់ស្រាផែនដី ចំនួន៤ដប តែឈ្មោះ សុភី មិនស្រវឹងទេ ដោយវាឈប់ផឹកមុនគេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ស៊ីម បានឆ្លើយថា: ខ្លួនដឹងតែរឿងក្រោយពេលគេយកសពមកដល់ផ្ទះហើយប៉ុណ្ណោះ រឿងក្រៅពីនេះ ខ្លួនមិនបានដឹងទេ។ ភូមិនោះធ្លាប់មានបាត់មាន់ដែរ តែគឺបាត់មុនពេលឈ្មោះ[redacted] ភារុណ មករស់នៅ ហើយក្រោយឈ្មោះនេះមករស់នៅគឺមិនដែលមានបាត់មាន់ទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារី បានឆ្លើយថា: ខ្លួនដឹងតែរឿងក្រោយពេលគេយកសពមកដល់ផ្ទះហើយប៉ុណ្ណោះ រឿងក្រៅពីនេះ ខ្លួនមិនបានដឹងទេ។ ដើមស្វាយនោះជាដើមស្វាយរបស់ខ្លួន។ ខ្លួនមិនបានឮថា ឈ្មោះ [redacted] ភារុណ បានភ្ជាប់ចរន្តអគ្គិសនីនៅនឹងរបងទេ។ ផ្ទះឈ្មោះ [redacted] ភារុណ មានគ្នាប្រហែលពី៤ទៅ៥នាក់។ តាំងពីឈ្មោះនេះមករស់នៅភូមិនេះ ផ្ទះគាត់មិនដែលបាត់មាន់ទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ថន បានឆ្លើយថាៈ ខ្លួនដឹងតែរឿងក្រោយពេលគេយកសពមកដល់ផ្ទះហើយប៉ុណ្ណោះ រឿងក្រៅពីនេះ ខ្លួនមិនបានដឹងទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីមុំ បានឆ្លើយថាៈ ខ្លួនជាប្រពន្ធឈ្មោះ [redacted] ការុណា។ ផ្ទះខ្លួនមានគ្នា៥នាក់ ហើយមានលក់នំបន្តិចបន្តួចនៅមុខផ្ទះ ខ្លួនមិនដែលឮប្តីខ្លួននិយាយប្រាប់ក្មេងណាថាៈ "កុំឱ្យទៅលេងជិតរបងទេ" ហើយប្តីខ្លួនក៏មិនដែលប្រាប់ខ្លួនថា គាត់មានតចរន្តអគ្គិសនីនៅនឹងរបងដែរ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] តាន បានឆ្លើយថាៈ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ម៉ោងប្រហែល៦ព្រឹក ខ្លួនបានឮឈ្មោះ តា និង ឈ្មោះ ថន រត់ទៅប្រាប់ឈ្មោះ ផុក ថា ប្អូនឯងឈ្មោះ ភី ស្លាប់ហើយ ពេលនោះ ខ្លួនបានដើរទៅមើលនឹងគេដែរ។ ពេលទៅដល់កន្លែងកើតហេតុ ខ្លួនបានឃើញសពឈ្មោះ សុភី ស្លាប់ដោយចង្កាសពគងលើរបងផ្ទះផ្ងាក់ក្រោមគេបង្អស់ ហើយនៅក្បែរសាកសពមានផ្លែស្វាយពីរ។ របងផ្ទះនោះមានព័ទ្ធលួស របៀបជាខ្សែអង់ទែនទូរទស្សន៍។ ខ្លួនពុំធ្លាប់ដឹងថា ផ្ទះនោះដាក់ចរន្តអគ្គិសនីភ្ជាប់ទៅនឹងខ្សែលួសរបងនោះទេ។ ខ្លួនបានជួយលើកសាកសពឈ្មោះ ភី មកតម្កល់ទុកនៅផ្ទះឈ្មោះ ផុក ត្រូវជាបងបង្កើត ហើយខ្លួនបានឃើញដៃសពម្ខាងមានស្នាមខ្លោចពីរ និង ម្ខាងទៀតមានស្នាមខ្លោចមួយ ស្នាមទាំងនោះ គឺជាស្នាមខ្សែភ្លើងឆក់។ ក្រៅពីនេះ ខ្លួនមិនបានដឹងអ្វីទៀតទេ។

-តាមសេចក្តីរាយការណ៍របស់សមត្ថកិច្ច ឈ្មោះ [redacted] សារឿន បានឆ្លើយថាៈ ថ្ងៃទី២០ ម៉ោង៦និង៣០នាទីព្រឹក ខ្លួនបានទទួលដំណឹង និង បានចុះដល់កន្លែងកើតហេតុ នៅម៉ោង៨និង៣០នាទីព្រឹក។ នៅនឹងបន្លានោះមានស្នាមឈាមខ្លោច និង អាវយឺតមួយនៅជាប់នឹងរបងនោះ ហើយឃើញមានផ្លែស្វាយ២ផ្លែនៅជ្រុងខាងកើត បន្លាដែលចងនៅនឹងរបងនោះ គឺលួសអង់ទែនចាស់យកមកធ្វើ។ ខ្លួនមិនបានឃើញមានខ្សែភ្លើងអ្វីទេ គ្រាន់តែឃើញថា មានភ្ជាប់លួសពីរបងទៅនឹងបង្គោលរោងក្បែរនោះ។ ផ្ទះ[redacted]ការុណា មានរបងតែ៣ជ្រុងទេ នៅមុខផ្ទះគ្មានរបងទេ។ ពេលចុះទៅនោះ គ្មានឃើញមានឌុយខ្សែភ្លើងអ្វីទេ។ ខ្លួនអាចសន្និដ្ឋានបានថា ជនរងគ្រោះស្លាប់ដោយឆក់ចរន្តអគ្គិសនី។ អាវយឺតនោះជារបស់ជនរងគ្រោះ។ ពុំមានខ្សែណាដែលអាចដាច់បណ្តាលឱ្យឆ្លងអគ្គិសនីទៅនឹងរបងនោះទេ។ នៅនឹងរបងមានភ្ជាប់ខ្សែលួសទៅនឹងរោងដែលអាចឱ្យមានភាពងាយស្រួលដែលអាចភ្ជាប់ចរន្តអគ្គិសនីទៅនឹងរបងនោះទាំងមូលបាន។

-តាមសេចក្តីរាយការណ៍របស់សមត្ថកិច្ចឈ្មោះ [redacted] សុខន បានឆ្លើយថាៈ ពេលពួកខ្លួនទៅដល់ កន្លែងកើតហេតុមានភាពប្រែប្រួលហើយ។ ក្រោយការពិនិត្យ គឺមិនឃើញមានខ្សែភ្លើងដែលអាចតភ្ជាប់ទៅនឹងរបងនោះ ពីផ្ទះឈ្មោះ [redacted] ការុណា នោះទេ តែនៅលើដំបូលស័ង្កសីរបស់ផ្ទះឈ្មោះ [redacted] ការុណា គឺមានខ្សែភ្លើងមានស្រោប ដែលភ្ជាប់ចរន្តអគ្គិសនីចូលទៅបន្ទប់ទឹកនៅជិតចង្ក្រានបាយ ហើយនៅនឹងចង្ក្រានបាយនោះ មានចងខ្សែលួសសម្រាប់ហាលខោអាវភ្ជាប់ទៅដល់របងបន្លាលួសជុំវិញផ្ទះ។ ប៉ុន្តែខ្លួនមិនបានពិនិត្យថា ខ្សែភ្លើងដែលនៅលើដំបូលនោះ មានភាពដាច់រលាត់ ឬរអត់នោះទេ។ នៅយប់នោះ គឺមានភ្លៀងធ្លាក់ និង ខ្យល់ខ្លាំង ដែលប្រហែលជាអាចមានទឹកហូរកាត់ ធ្វើឱ្យកកឹតដែលអាចឱ្យមានការឆ្លងចរន្តអគ្គិសនី។



CS CamScanner

-តាមសេចក្តីរាយការណ៍របស់សមត្ថកិច្ចឈ្មោះ [redacted] វណ្ណា បានឆ្លើយថាៈ ក្រោយកើតហេតុនៅវេលាម៉ោង៦ជាងព្រឹក ខ្លួនបានទទួលទូរស័ព្ទអនាមិកប្រាប់ពីហេតុការណ៍នេះ ខ្លួនក៏បានចុះទៅពិនិត្យមើល តែខ្លួនមិនបានឃើញសាកសពទេ។ នៅយប់ថ្ងៃកើតហេតុនោះ គឺពិតជាមានភ្លៀងធ្លាក់ និង ខ្យល់បក់យ៉ាងខ្លាំងពិតមែន។

-តាមសេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការថាៈ ក្រោយពីការដេញដោល ពិនិត្យភស្តុតាង ឃើញថា កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង៩និង៣០នាទីយប់ឈានចូលថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង៦ព្រឹក នៅចំណុចភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត មានអំពើ ឃាតកម្មគិតទុកជាមុន ដែលបង្កឡើងដោយឈ្មោះ ម៉ន ការុណ បានដាក់បង្គៃខ្សែភ្លើងតាមរបង ហើយត្រូវបានឈ្មោះ [redacted] សុភី ដើរទៅប៉ះបណ្តាលឱ្យស្លាប់ ដែលអំពើនេះច្បាប់បានបញ្ញត្តិថា ជាបទល្មើស និង ត្រូវផ្តន្ទាទោសតាមច្បាប់ តាមចម្លើយដោះសាររបស់ជនជាប់ចោទ ពុំមានហេតុផលណាមួយដែលអាចឱ្យជឿបាននោះទេ បើឈ្មោះ [redacted] ការុណមិនបានដាក់ខ្សែភ្លើងទេនោះ ក៏មិនបណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] សុភី ស្លាប់ដែរ។ តាមចម្លើយសាក្សីដោះបន្ទុករបស់ជនជាប់ចោទ ក៏មិនបានបង្ហាញឱ្យច្បាស់អំពីព្រឹត្តហេតុរបស់ជនជាប់ចោទដែរ ការប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ សន្តិសុខ និង របៀបរៀបរយសាធារណៈ។ ឃើញថា បងរបស់ជនរងគ្រោះ ឈ្មោះ [redacted] ប៊ុន្នី បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ។ ដូច្នេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ពីបទ ឃាតកម្មគិតទុកជាមុន តាមដីកាសន្និដ្ឋានស្ថាពរ លេខ៣៦ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ទុកជាបានការពេញទាំងមូល។

-តាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវីថាៈ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ ចម្លើយជនជាប់ចោទ ចម្លើយសាក្សី សេចក្តីរាយការណ៍របស់សមត្ថកិច្ច ឃើញថា កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ ពិតជាមានអំពើ ឃាតកម្មគិតទុកជាមុន កើតឡើងនៅចំណុចភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ពិតប្រាកដមែន។ ប៉ុន្តែ តាមចម្លើយជនជាប់ចោទនៅគ្រប់ដំណាក់កាល និង សវនាការនាពេលនេះ កូនក្តីខ្លួនបានបញ្ជាក់អះអាងដដែលៗថា ខ្លួនមិនបានប្រាប់ពីរឿងដាក់ខ្សែភ្លើងនៅរបងទៅឈ្មោះ [redacted] ៣ នោះទេ។ តាមចម្លើយសាក្សីឈ្មោះ [redacted] គា , ឈ្មោះ [redacted] មនសិកា , ឈ្មោះ [redacted] ៣ និង ឈ្មោះ [redacted] កំនំថន គឺមិនមានភស្តុតាងដាក់បន្ទុកណាមួយ ដែលអាចបញ្ជាក់បានថា កូនក្តីរបស់ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ។ តាមចម្លើយបញ្ជាក់របស់សាក្សីឈ្មោះ [redacted] ស៊ីយ និង ឈ្មោះ [redacted] ណារី បានបង្ហាញថា កូនក្តីខ្លួនជាមនុស្សមិនដែលចេះមានបញ្ហាជាមួយអ្នកភូមិនោះទេ។ ដូច្នេះ ខ្លួនសុំស័ណ្ឋមពរដល់លោកប្រធានក្រុមប្រឹក្សាមេត្តាពិនិត្យ និង ពិចារណាឱ្យកូនក្តីខ្លួន បានរួចផុតពីបទចោទប្រកាន់ ឃាតកម្មគិតទុកជាមុន ដោយក្តីអនុគ្រោះ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី និង អំណានចម្លើយរបស់សាក្សីអវត្តមាន

-ក្រោយពីបានសេចក្តីរាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**សាលាដំបូងខេត្តកំពត**

**ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា:**

-កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ នៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ចន្លោះពីម៉ោង២១និង៣០នាទីទៅម៉ោង៦ព្រឹកឈានចូលថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ [redacted] សុភី បានឆក់ខ្សែភ្លើងស្លាប់ក្បែរបេងលួសផ្ទះ [redacted] ការុណា។ ឆ្លងតាមការស្រាវជ្រាវរបស់សមត្ថកិច្ចនគរបាលលើសាក្សី និង ពិនិត្យកន្លែងកើតហេតុ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ការុណា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ បញ្ជូនមកសាលាដំបូងឃុំខ្លួនរហូតដល់សព្វថ្ងៃ។

-ឆ្លងតាមសវនាការបាន បង្ហាញឱ្យឃើញថា នៅយប់ថ្ងៃកើតហេតុទី១៩ ខែមីនា ឆ្នាំ២០០៩ មានភ្លៀងធ្លាក់ និង មានផ្គររន្ទះ ខ្យល់បក់បោកយ៉ាងខ្លាំង ដែលអាចបណ្តាលឱ្យខ្សែភ្លើងនៅលើដំបូលផ្ទះបាយប្រក់ស័ង្កសីរបស់ឈ្មោះ [redacted] ការុណា កកិតប៉ះទៅនឹងដំបូលបណ្តាលឱ្យបេកស្រោមធ្វើឱ្យមានការឆ្លងចរន្តអគ្គិសនី តាមខ្សែលួសហាលខោអាវដែលចងភ្ជាប់ចេញពីផ្ទះបាយទៅនឹងរបងលួសដែលព័ទ្ធជុំវិញផ្ទះ បណ្តាលឱ្យឆក់ស្លាប់ជនរងគ្រោះ ដែលនេះអាចកំណត់បានថា ជាករណីប្រធានសក្តិ។

-តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និង កំណត់ហេតុពិនិត្យកន្លែងកើតហេតុ មានភាពស៊ីសង្វាក់គ្នា ដែលអាចកំណត់បានថា មានការឆក់ចរន្តអគ្គិសនីនៅនឹងរបងបន្លាលួស បណ្តាលឱ្យស្លាប់ឈ្មោះ [redacted] សុភីពិតប្រាកដមែន តែពុំមានភាពស៊ីសង្វាក់គ្នា ដែលអាចឱ្យតុលាការយកជាការបាន ដើម្បីកំណត់ថាឈ្មោះ [redacted] ការុណា ជាជនបានប្រព្រឹត្តបទល្មើសឡើយ។

-នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចំពោះមុខចៅក្រមស៊ើបសួរ និង ចំពោះមុខតុលាការនាពេលសវនាការ ជនជាប់ចោទបានឆ្លើយបដិសេធន៍នូវការប្រព្រឹត្តដែលតំណាងអយ្យការបានចោទប្រកាន់ ពីបទ ឃាតកម្មគិតទុកជាមុន កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ នាពេលសវនាការពុំមានចម្លើយសាក្សីណាម្នាក់ដែលបានឃើញច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] ការុណា ជាអ្នកយកភ្ជាប់ចរន្តអគ្គិសនីទៅនឹងរបងលួសដែលបណ្តាលឱ្យស្លាប់ជនរងគ្រោះឡើយ។

-តាមមតិរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការ មានហេតុផលសមស្របអាចឱ្យតុលាការជឿ និង យកជាការបាន។

-ការចោទប្រកាន់លើជនជាប់ចោទ គឺគ្រាន់តែជាករណីសង្ស័យតែប៉ុណ្ណោះ តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

-គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ការុណា ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ បទល្មើស



CamScanner

ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ គប្បីឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ និង ផ្តន្ទាទោស។

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពត

## វិនិច្ឆ័យសេចក្តី

ឱ្យឈ្មោះ [redacted] ភារុណ ភេទប្រុស អាយុ២៨ឆ្នាំ រួចខ្លួនពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២ និង យោងតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខគូភាគី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

ក្រឡាចំណារ

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពត, ថ្ងៃទី.......ខែ.......ឆ្នាំ២០១...

[redacted]